# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩

## យុវជនបរិស្ថានជំរុញឱ្យរាជរដ្ឋាភិបាល វិស័យឯកជន យុវជន និងសាធារណៈជនទូទៅ យកចិត្តទុកដាក់ និងចូលរួមជាសកម្មភាពបន្ថែមទៀតក្នុងការចូលរួមទប់ស្កាត់ការប្រែប្រួលអាកាសធាតុតាមរយៈការការពារធនធានធម្មជាតិ និងចូលរួមកាត់បន្ថយការបំភាយឧស្ម័នកាបូនឌីអុកស៊ីតទៅក្នុងបរិយាកាស

យើងខ្ញុំជាតំណាងជាអង្គការ សមាគមយុវជន និងយុវជនបរិស្ថានចំនួន៣៦១ នាក់ (ស្រី ២២០នាក់) ដែលបានចូលរួមអបអរសាទរ និងប្រារព្ធកម្មវិធីទិវាបរិស្ថានពិភពលោកខួបលើកទី៤៧ ក្រោមប្រធានបទ "**ការពារភពផែនដីដើម្បីទាំងអស់គ្នា**" ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ។ យើងខ្ញុំសូមសម្តែងក្តីបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពនៃការទទួលរងឥទ្ធិពលអវិជ្ជមានពីការប្រែប្រួលអាកាសធាតុមកលើប្រទេសកម្ពុជា ដែលកំពុងបង្កផលប៉ះពាល់ដល់សុខភាព ការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជា ជាពិសេសការប្រកបមុខរបរធ្វើកសិកម្ម និងប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមផ្សេងទៀត។ តាមរយៈការពិភាក្សារបស់យុវជន យើងមើលឃើញថាការបាត់បង់ព្រៃឈើ ធនធានធម្មជាតិ ការបំពុលទន្លេនិងសមុទ្រពីគម្រោងអភិវឌ្ឍន៍នានា ការគ្រប់គ្រងសំរាម និងកាកសំណល់មិនទាន់បានល្អប្រសើរ បានកំពុងធ្វើឱ្យប៉ះពាល់បរិស្ថាននិងរួមចំណែកដល់ការប្រែប្រួលអាកាសធាតុនិងការរក្សាភាពធន់ទល់នឹងការប្រែប្រួលអាកាសធាតុរបស់ប្រជាពលរដ្ឋកម្ពុជា។

## តាមរយៈការបង្ហាញខាងលើយើងទទួលស្គាល់ថា៖

- សារៈសំខាន់នៃព្រៃឈើ ធនធានធម្មជាតិ ទន្លេ និងការប្រើប្រាស់ថាមពលស្អាត គឺមានសារៈសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកបរិស្ថាន និងចូលរួមប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ។
- តួនាទីរបស់យុវជនក្នុងការការពារ ទឹក ដី និងព្រៃ គឺពិតជាមានឥទ្ធិពលក្នុងការរួមចំណែកដោះស្រាយបញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ។
- តួនាទីរបស់យុវជនជាស្ត្រីពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិរក្សធនធានធម្មជាតិ។
- បញ្ហាប្រឈមនានារបស់យុវជនក្នុងការចូលរួមការពារបរិស្ថានដែលពាក់ព័ន្ធនៅក្នុងគម្រោងអភិវឌ្ឍន៍នានា មានដូចជាការទាញយកធនធានរ៉ែ ដីសម្បទានសេដ្ឋកិច្ច ការកាប់បំផ្លាញព្រៃឈើ និងការសាងសង់ទំនប់វារីអគ្គិសនី។
- ការគោរព និងអនុវត្តន៍ច្បាប់ បទបញ្ញត្តិនានា និងគោលនយោបាយពាក់ព័ន្ធនិងកិច្ចការពារបរិស្ថានឱ្យបានពេញលេញ នឹងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

## យើងសូមសម្តែងការព្រួយបារម្ភចំពោះ៖

- ការប្រើប្រាស់ប្លាស្ទិក ការគ្រប់គ្រងកាកសំណល់ និងឥរិយាបទរបស់ប្រជាជនក្នុងការប្រើប្រាស់ថង់ផ្លាស្ទិកច្រើនលើសពីតម្រូវការចាំបាច់ ព្រមទាំងការគ្រប់គ្រងនិងទុកដាក់កាកសំណល់សម្រាមនៅទីសាធារណៈពុំបានត្រឹមត្រូវ។
- ការបន្តបាត់បង់ធនធានធម្មជាតិក្រោមគម្រោងអភិវឌ្ឍន៍ធំៗមានដូចជា គម្រោងដីសម្បទានសេដ្ឋកិច្ច សម្បទានរ៉ែ និងការបាត់បង់ព្រៃឈើដោយសារការកាប់បំផ្លាញបែបអណាធិបតេយ្យ និងការទន្ទ្រានដីព្រៃខុសច្បាប់ ហើយការអនុវត្តច្បាប់នៅមានកម្រិត។ ជាក់ស្តែងយោងតាមរបាយការណ៍របស់អង្គការលីកាដូរ គិតមកដល់បច្ចុប្បន្ន ដីសម្បទានសរុបមានប្រមាណ ២.៣៨៤,១៣៥ ហិកតាក្នុងដីសម្បទានចំនួន ២៧៣ កន្លែង។ លើសពីនេះ នៅចន្លោះឆ្នាំ១៩៧៣ គម្របព្រៃឈើធម្មជាតិនៅកម្ពុជាមានប្រមាណ ១៣.១៤ លានហិកតា ប៉ុន្តែវាបានធ្លាក់ចុះយ៉ាងគំហុកនៅពីរទសវត្សចុងក្រោយនេះ មកសល់ត្រឹមប្រមាណ៨.៩ លានហិកតា[1]។
- កំណើននៃការបំពុលខ្យល់តាមរយៈ រោងចក្រឧស្សាហកម្មដែលមាននៅក្នុងរាជធានីភ្នំពេញ និងកំណើននៃការប្រើប្រាស់ផូស៊ីលឥន្ធនៈ។ ជាពិសេស គឺការទាញយកថាមពលអគ្គិសនីដើរដោយថាមពលធ្យូងថ្មដើម្បីទាញយកថាមពលអគ្គិសនីក្នុងការផ្គត់ផ្គង់តម្រូវការនិងការខ្វះខាតផ្នែកអគ្គិសនីរបស់កម្ពុជា និងដើម្បីរក្សាកំណើននៃការអភិវឌ្ឍសេដ្ឋកិច្ច។ ក្រៅពីផលប្រយោជន៍នៃការទាញយកថាមពលអគ្គិសនីពីថាមពលធ្យូងថ្មនេះ កម្ពុជាក៏បានរួមចំណែកក្នុងការបំភាយឧស្ម័នកាបូនឌីអុកស៊ីត (CO2) ទៅក្នុងបរិកាសដូចប្រទេសអភិវឌ្ឍន៍ផ្សេងទៀតផងដែរ។ ចំណុចនេះ យើងបារម្ភថាកម្ពុជាពុំទាន់បានអនុវត្តន៍ការប្តេជ្ញាចិត្តនិងការសន្យារបស់ខ្លួននៅក្នុងសន្និសីទពិភពលោកស្តីពីការប្រែប្រួលអាកាសធាតុ COP21 នៅទីក្រុងប៉ារីស កាលពីឆ្នាំ២០១៦ ក្នុងការចូលរួម កាត់បន្ថយការការបំភាយឧស្ម័នកាបូនឌីអុកស៊ីត (CO2) តាមរយៈការរក្សាគម្របព្រៃឈើធម្មជាតិនិងពង្រីកគម្របព្រៃឈើបន្ថែម។
- កំណើននៃការប្រើប្រាស់ថ្នាំពុលនៅក្នុងវិស័យកសិកម្មនៅកម្ពុជាដោយពុំទាន់មានបច្ចេកទេស និងការត្រួតពិនិត្យឱ្យបានត្រឹមត្រូវដែលបានកំពុងបង្កើតឱ្យមានការព្រួយបារម្ភចំពោះសុវត្ថិភាពចំណីអាហារ និងសុខភាពសាធារណៈរបស់ពលរដ្ឋកម្ពុជា។
- ការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងវិស័យធនធានធម្មជាតិដូចជាច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាល ច្បាប់ស្តីពីកិច្ចគាំពារបរិស្ថាននិងធនធានធម្មជាតិ ពុំសូវមានប្រសិទ្ធភាពដែលជាហេតុធ្វើឱ្យបទល្មើសនៃការកាប់បំផ្លាញព្រៃឈើនិងការទន្ទ្រានដីសាធារណៈមិនមានការថយចុះទាំងនៅក្នុងតំបន់អភិរក្ស និងព្រៃបម្រុងទុកអចិន្ត្រៃយ៍ តាមរយៈការចេញផ្សាយរបាយការណ៍របស់អង្គការសង្គមស៊ីវិល ការរាយការណ៍របស់សហគមន៍មូលដ្ឋាន និងការចុះផ្សាយរបស់សារព័ត៌ផ្សេងៗ។ ឧទាហរណ៍៖ បទល្មើសព្រៃឈនៅក្នុងតំបន់អភិរក្សដែនជំរកសត្វព្រៃព្រៃឡង់ ព្រៃព្រះរកា និងតំបន់អភិរក្សផ្សេងៗទៀត។
- ការទន្ទ្រាន និងលុបដីសមុទ្រផងនៅឆ្នេរព្រៃកោងកាងខេត្តព្រះសីហនុ និងការបោះបង្គោលលើដីសមុទ្រទំហំជាង ១ ហិកតា ស្ថិតនៅសង្កាត់ត្រើយកោះ ក្រុង-ខេត្តកំពត។
- ការបង្ហូរកាកសំណល់រាវដោយសារកំណើននៃការអភិវឌ្ឍន៍ទីក្រុង ការសាងសង់អគារ សណ្ឋាគារ កាស៊ីណូច្រើនដែលពុំបានពង្រីកប្រព័ន្ធប្រព្រឹត្តកម្មទឹកទុកជាមុន ជាហេតុធ្វើអោយមានការបង្ហូរទឹកកខ្វក់ចូលទៅក្នុងសមុទ្រ។ ជាក់ស្តែងការបង្ហូរកាកសំណល់រាវទៅក្នុងសមុទ្រនៅក្នុងខេត្តកំពង់សោម និងកោះរ៉ុងជាដើម។

---

[1] យោងតាមទិន្នន័យរបស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia)

- ការវិនិយោគលើគម្រោងទំនប់វារីអគ្គិសនីខ្នាតធំដែលគម្រោងទាំងនេះបានធ្វើឱ្យមានការបាត់បង់ព្រៃឈើ ការថយចុះទិន្នផលត្រី ប៉ះពាល់ដល់គុណភាពទឹក និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិរបស់ទន្លេ។ ជាក់ស្តែងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោមពីរដែលមានថាមពល៤០០ មេហ្គាវ៉ាត់ ក៏បានធ្វើឱ្យបាត់បង់ព្រៃឈើប្រមាណ ៣០០០០ ហិកតា ការបិទផ្លូវចរាចរណ៍របស់ត្រីដែលនឹងធ្វើឱ្យប៉ះពាល់ដល់បរិមាណត្រីនៅអាងទន្លេមេគង្គផងដែរ និងការបណ្តេញចេញសហគមន៍ដែលរងផលប៉ះពាល់ជាង ៥០០០នាក់ (មួយចំនួន ជាជនជាតិដើមភាគតិច កំពុងរស់នៅក្នុងភូមិចាស់ដែលកំពុងជន់លិចដោយសារទឹកពីអាងស្តុកទឹកទំនប់នេះ)។ លើសពីនេះ យើងក៏មានការព្រួយបារម្ភផងដែរចំពោះភាពមិនច្បាស់លាស់នៃគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីចំនួន២ ទៀត នៅដងទន្លេមេគង្គ គឺគម្រោងទំនប់វារីអគ្គិសនីសំបូរ និងស្ទឹងត្រែង។ យោងតាមរបាយការណ៍របស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលទឹកសាប បានបង្ហាញក្តីបារម្ភសម្រាប់ធ្វើការពិចារណាទៅលើផលប៉ះពាល់ទៅលើសន្តិសុខស្បៀងនៅកម្ពុជា ការប៉ះពាល់លើអាហារូបត្ថម្ភ និងធ្លាក់ចុះធនធានជលផលពីចន្លោះ ១៦%ទៅ៣១% ដោយសារតែការកាត់ផ្តាច់ការធ្វើបំលាស់ទីរបស់ត្រីទៅខ្សែរទឹកខាងលើ។ បទពិសោធន៍នៃការបាក់ទំនប់វារីអគ្គិសនៅនៅប្រទេសឡាវ និងប្រទេសប្រេស៊ីល គឺជាគ្រោះមហន្តរាយមួយដែលកម្ពុជាគួរពិចារណាចំពោះផែនការសាងសង់គម្រោងទំនប់វារីអគ្គិសនីបន្ថែមទៀតនៅកម្ពុជា។

## យើងសូមស្វាគមន៍ចំពោះ

- ការបង្កើតឧទ្យានជាតិ ព្រៃតំបន់ការពារនិងតំបន់អភិរក្សដែនជម្រកសត្វព្រៃបន្ថែមដែលមានប្រមាណ ៧.៥ លានហិកតា[2]។ ប៉ុន្តែបើយោងតាមរបាយការណ៍របស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) តំបន់ការពារនៅកម្ពុជាមានទំហំប្រមាណ ៦,២៦៨,២៦១ ហិកតា។ ការផ្តល់សិទ្ធិនិងការទទួលស្គាល់ព្រៃសហគមន៍ចំនួន៦១០ សហគមន៍ នេសាទចំនួន៥១៦ ការបង្កើតតំបន់អេកូទេសចរណ៍ធម្មជាតិ និងការបន្តជ្រើសរើសនិងកសាងសមត្ថភាពដល់មន្ត្រីឧទ្យានុរក្សបន្ថែម។
- ការអំពាវនាវរបស់រាជរដ្ឋាភិបាលឱ្យមានការចូលរួមពីសាធារណៈជនក្នុងកិច្ចការពារបរិស្ថាន ជាពិសេសគឺការចេញសារាចរណែនាំលេខ០៥ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពី វិធានការចាំបាច់ក្នុងការពង្រឹងការការពារធនធានធម្មជាតិ។
- ការបង្កើននិងបើកឱ្យមានការវិនិយោគលើការទាញយកថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យនៅកម្ពុជា។ ឧទាហរណ៍៖ សួនថាមពលពន្លឺព្រះអាទិត្យដំបូងគេបង្អស់នៅកម្ពុជាដែលមានអនុភាព១០ មេហ្គាវ៉ាត់ (MW) នៅខេត្តស្វាយរៀង គម្រោងទាញយកថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យចំនួន៦០ មេហ្គាវ៉ាត់នៅខេត្តកំពង់ស្ពឺ និងគម្រោងផ្សេងៗទៀត។
- ការទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់យុវជន និងសហគមន៍ក្នុងការចូលរួមការពារធនធានធម្មជាតិ។
- ការប្តេជ្ញាចិត្តខិតខំប្រឹងប្រែងក្នុងការរៀបចំតាក់តែងក្រមបរិស្ថាន រហូតដល់សេចក្តីព្រាងទី១១។
- ការផ្តួចផ្តើមនិងដំណើរការនៃការធ្វើវិសោធនកម្មច្បាប់ទាំង៣ គឺច្បាប់ស្តីពី ព្រៃឈើ ច្បាប់ជលផល និងច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ។

---

[2] លោក គង់ សៀកលី ប្រធាននាយកដ្ឋាន ជីវភាពសហគមន៍នៃក្រសួងបរិស្ថាន លើកឡើងថាដីព្រៃតំបន់ ការពារមាន៧លាន ៥សែនហិកតា។ សូមមើលព័ត៌មានលំអិត៖ http://tinyw.in/RFhw

- ការបង្កើតគោលនយោបាយ និងការចេញលិខិតបទដ្ឋានណែនាំឱ្យមានកាត់បន្ថយប្លាស្ទិកនៅតាមផ្សារ និងម៉ាតនៅរាជធានីភ្នំពេញ។
- ការបង្កើនចំនួនធុងសំរាមតាមទីសាធារណៈក្នុងរាជធានីភ្នំពេញ។
- ការដាំ និងស្តារព្រៃឈើឡើងវិញ និងការដកហូតនិងលុបដីសម្បទាននៅតំបន់ព្រៃឈើចូលជាសម្បត្តិរដ្ឋវិញ។

***ដូច្នេះហើយ តាមរយៈសេចក្តីថ្លែងការណ៍នេះយើងសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធខាងក្រោម៖***

## ១. រាជរដ្ឋាភិបាល

- បង្កើតការវិនិយោគថាមពលស្អាតនិងកកើតឡើងវិញដូចជាការទាញយកថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ប្រសើរជាងការប្រើប្រាស់ថាមពលធ្យូងថ្ម និងទំនប់វារីអគ្គិសនីខ្នាតធំ។
- បើកចំហរ និងផ្សព្វផ្សាយព័ត៌មាននិងទិន្នន័យអំពីគម្រោងអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិឱ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធ។
- ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងការបំពេញមុខងាររបស់អាជ្ញាធរពាក់ព័ន្ធនឹងការការពារធនធានធម្មជាតិ
- ពង្រឹងយន្តការតាមដានដានការអនុវត្តច្បាប់របស់មន្ត្រី ឬអាជ្ញាធរមូលដ្ឋាន និងបង្កើតយន្តការបណ្តឹងពីសាធារណៈជនចំពោះការបំពេញមុខងាររបស់មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធបញ្ហាបរិស្ថាន និងធនធានធម្មជាតិ។
- សូមបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចទាំងស្រុង និងបន្តការធ្វើអធិការកិច្ចឱ្យមានតម្លាភាពចំពោះក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងសម្បទានរ៉ែដែលកំពុងប្រតិបត្តិការទាំអស់។
- ជំរុញការអនុវត្តនិងត្រួតពិនិត្យពីដំណើរការនៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននិងសង្គមគ្រប់គម្រោងអភិវឌ្ឍន៍ឱ្យមានតម្លាភាព និងតម្រូវឱ្យក្រុមហ៊ុនស្តារបរិស្ថានជាចាំបាច់ក្រោយបញ្ចប់គម្រោងអភិវឌ្ឍន៍។
- ស្នើសុំបញ្ឈប់ការចោទប្រកាន់លើសកម្មជនបរិស្ថានថាជាក្រុមគណបក្សនយោបាយណាមួយ។
- សូមអំពាវនាវដល់រាជរដ្ឋាភិបាលផ្តល់ការគាំទ្រ លើកទឹកចិត្ត និងការពារអ្នកការពារបរិស្ថាន និងព្រៃឈើដើម្បីឱ្យពួកគេអាចធ្វើការងាររបស់ខ្លួនដោយគ្មានការភ័យខ្លាច។
- ស្នើរាជរដ្ឋាភិបាលបង្កើនកញ្ចប់ថវិកាសម្រាប់សកម្មភាពការពារធនធានធម្មជាតិ និងបរិស្ថាន។
- បង្កើនការអប់រំអំពីបរិស្ថាននិងការចូលរួមការពារបរិស្ថានទាំងក្នុងនិងក្រៅប្រព័ន្ធឱ្យបានទូលំទូលាយ។
- បង្កើនការដាំដើមឈើឱ្យបានច្រើននៅលើដីដែលមានព្រៃរេចរឹល ឬនៅតំបន់ដីសម្បទានសេដ្ឋកិច្ចដែលបានដកហូតហើយមានព្រៃរេចរឹល។
- សូមធ្វើការបែងចែកការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល និងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ចំពោះការការពារធនធានធម្មជាតិ។
- បង្កើតរោងចក្រកែច្នៃសំរាម និងបង្កើតគោលនយោបាយតំឡើងពន្ធលើប្លាស្ទិកនិងកាត់បន្ថយការប្រើប្រាស់។
- ផ្តល់សិទ្ធិវិនិយោគដល់ក្រុមហ៊ុនដែលមានកេរ្តិ៍ឈ្មោះល្អៗក្នុងការពារបរិស្ថាន និងសង្គម។

## ២. វិស័យឯកជន

- ត្រូវបង់ពន្ធ គោរពច្បាប់បរិស្ថានឱ្យបានត្រឹមត្រូវ និងគ្រប់គ្រងសំណល់របស់ខ្លួនឱ្យមានប្រសិទ្ធភាព។
- គួរកាត់បន្ថយការវេចខ្ចប់ប្លាស្ទិកទៅលើផលិតផលរបស់ខ្លួន។
- គួរសាងសង់រោងចក្រឧស្សាហកម្មឱ្យឆ្ងាយពីទីក្រុងដើម្បីកាត់បន្ថយការបំពុលសំឡេង និងខ្យល់នៅក្នុងទីក្រុង
- បញ្ឈប់ការនាំចូលយានយន្តចាស់ៗ។
- រាល់ក្រុមហ៊ុនសាជីវកម្មត្រូវមានទំនួលខុសត្រូវសង្គមចំពោះសង្គម និងបរិស្ថាន។

## ៣. អង្គការសង្គមស៊ីវិល

- បង្កើនថវិកា និងសកម្មភាពក្នុងកិច្ចការពារបរិស្ថាន។
- ស្នើឱ្យអង្គការសង្គមស៊ីវិល បង្កើនការគាំទ្រសកម្មជនគ្រប់រូបភាពទាំងផ្លូវកាយ ផ្លូវចិត្ត និងថវិកាសម្រាប់ធ្វើសកម្មភាពការពារព្រៃឈើ និងធនធានធម្មជាតិ។
- បង្កើតយន្តការធ្វើការងាររួមគ្នាក្នុងវិស័យបរិស្ថាន។
- ចូលរួមតាមដានយន្តការដែលមានស្រាប់របស់រដ្ឋឱ្យមានប្រសិទ្ធិភាព។
- តម្លាភាព និងគណនេយ្យភាពនៃការប្រតិបត្តិការការងាររបស់ខ្លួន។
- ផ្តល់ការគាំទ្រសកម្មភាពសហគមន៍ និងយុវជនដែលធ្វើការការពារធនធានធម្មជាតិនៅកម្រិតមូលដ្ឋានពិតប្រាកដ។

## ៤. យុវជន និងសាធារណៈជនទូទៅ៖

- កាត់បន្ថយការប្រើប្រាស់ ប្រើនិងកែច្នៃឡើងវិញ ព្រមទាំងបដិសេធន៍ចំពោះការប្រើប្រាស់ផ្លាស្ទិក។
- ចូលរួម និងចាប់ផ្តើមកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក។
- ចូលរួមដាំដើមឈើឡើងវិញ។
- បញ្ឈប់ការជួញដូរ និងការបរិភោគសត្វព្រៃ។
- គ្រប់គ្រងកាកសំណល់ឱ្យបានត្រឹមត្រូវ។
- ចូលរួមប្រើប្រាស់សេវាធ្វើដំណើរសាធារណៈដើម្បីរួមចំណែកកាត់បន្ថយការប្រើប្រាស់ផូស៊ីលឥន្ធនៈ និងកាត់បន្ថយការកកស្ទះចរាចរណ៍។

## សេចក្តីថ្លែងការណ៍នេះគាំទ្រដោយយុវជន និងអង្គការ សមាគមដូចខាងក្រោម៖

- ក្រុមយុវជនដើម្បីសង្គម (YS)
- សមាគមបណ្តាញយុវជនកម្ពុជា (CYN)
- អង្គការសមធម៌កម្ពុជា (EC)
- អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS)
- យុវជនដែលចូលរួមកម្មវិធីទិវាបរិស្ថានពិភពលោក នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៩ ចំនួន៣៦១ នាក់។

## សូមទំនាក់ទំនង៖

លោក **ភិន សាវ៉** អ្នកសម្របសម្រួលគម្រោងនៃ សមាគមបណ្តាញយុវជនកម្ពុជា (CYN)

លេខទូរស័ព្ទ៖ ០៩៦ ២៧៩ ៧០០៩